ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOUL GEAR

លេខៈ ២១០៤/២០

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ដឹ សូល ហ្គៀ (ខេមបូឌា) ឯ.ក
# និង
# តំណាងប្រតិភូបុគ្គលិក និងសហជីពកម្មករកម្ពុជាដើម្បីសេរីភាព ប្រចាំរោងចក្រ ដឹ សូល ហ្គៀ (ខេមបូឌា) ឯ.ក
# ស្តីអំពីការព្យួរការងារ

នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី នៅក្នុងរោងចក្រ ដឹ សូល ហ្គៀ(ខេមបូឌា) ឯ.ក មានកិច្ចប្រជុំមួយ រវាង តំណាងក្រុមហ៊ុន និង តំណាងកម្មករ សហជីពកម្មករកម្ពុជាដើម្បីសេរីភាព ប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ តំណាងនាយកក្រុមហ៊ុនបានជូនដំណឹងដល់បងប្អូនកម្មករ កម្មការិនីទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរោងចក្រថា ពេលនេះរោងចក្រមិនមានការបញ្ជាទិញគ្រប់គ្រាន់ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូល ដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរការងាររបស់បងប្អូនបុគ្គលិកកម្មករកម្មការិនីចំនួន ១ខែ(មួយខែ) គឺចាប់ពីថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០២០ ទៅដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២០ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ បងប្អូនកម្មករកម្មការិនីបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនដូចខាងក្រោមៈ

១-ក្រុមហ៊ុនផ្តល់ ប្រាក់ឧបត្ថម្ភចំនួន **៣០ដុល្លារ(ដប់ដុល្លាអាមេរិក)** ក្នុងរយៈពេលព្យួរ សម្រាប់កម្មករកម្មការិនីម្នាក់ៗ។

២-ចំពោះបុគ្គលិកការិយាល័យ និងបងប្អូននិយោជិតដែលមានប្រាក់ខែគោលលើសពី១៩០ដុល្លា ក្រុមហ៊ុននឹងផ្តល់ជូន៤០% នៃប្រាក់ខែគោលក្នុងរយៈពេលព្យួរកិច្ចសន្យាការងារនេះ។

៣-រដ្ឋាភិបាល ផ្តល់ប្រាក់ឧបត្ថម្ភចំនួន **៤០ ដុល្លា(ដប់ប្រាំដុល្លាអាមេរិក)** ក្នុងរយៈពេលព្យួរ សម្រាប់កម្មករ កម្មការិនីម្នាក់ៗ ។

អង្គប្រជុំបានចប់វេលាម៉ោង១៥និង៤៥នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ថ្ងៃអង្គារ ១៤រោជ ខែចែត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល, ថ្ងៃទី២១ ខែ មេសា ឆ្នាំ២០២០

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ដឹ សូល ហ្គៀ (ខេមបូឌា) ឯ.ក THE SOUL GEAR (CAMBODIA) CO.,LTD. KINGDOM OF CAMBODIA

# តំណាងប្រតិភូបុគ្គលិក និង តំណាងសហជីព

១.ជា មិនា ២.នុត ណុល ៣. យ៉ែម សុខា

៤.ជួន ចាន់ណារុំ ៥.សេង យឿន ៦. នៅ ណារី

៧.អាន ចំរើន ៨.ឡា ពិសី ភី សីហា